អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូង នឹងបន្តសវនាការលើភស្តុតាងក្នុង សំណុំរឿង ០០២ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងបន្តសវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២ ប្រឆាំងនឹងខៀវ សំផន, នួន ជា និងអៀង សារី នៅម៉ោង ៩:០០ នៅថ្ងៃអង្គារ ទី ១០ ខែ មករា ឆ្នាំ ២០១២។ សវនាការក្នុងពេលបន្ទាប់នេះ នឹងចាប់ផ្តើមពីថ្ងៃទី ១០ ខែ មករា រហូតដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូង នឹងផ្អាកមិនធ្វើសវនាការមួយរយៈពេល ហើយនឹងចាប់ផ្តើមបន្តសវនាការបន្តបន្ទាប់ទៀត នៅថ្ងៃចន្ទ ទី ១២ ខែ មីនា ឆ្នាំ ២០១២។

សវនាការនឹងបន្តធ្វើឡើងជាធម្មតា ពីថ្ងៃចន្ទ ដល់ថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ម៉ោង ១៦:០០ រសៀល។ អង្គជំនុំជម្រះ អាចនឹងកែប្រែកម្មវិធីនេះ ដោយធ្វើការជូនដំណឹងជាមុនក្នុងរយៈពេលដ៏ខ្លី ដូច្នេះ ភ្ញៀវទាំងអស់ ត្រូវតាមដានព័ត៌មាននៅលើគេហទំព័ររបស់ អ.វ.ត.ក (www.eccc.gov.kh) ដើម្បីទទួលដំណឹងពីកម្មវិធី ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត។

សាធារណជនអាចចូលរួមតាមដានសវនាការគ្រប់ពេល លើកលែងតែនៅពេលដែលអង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះត្រូវស្តាប់បញ្ហាជាក់លាក់មួយចំនួន នៅក្នុងសវនាការអសាធារណៈ។ កន្លែងអង្គុយនៅក្នុងសាលសវនាការសាធារណៈ នឹងត្រូវផ្តល់ជូនដោយផ្អែកលើគោលការណ៍ដែលថា អ្នកមកមុន នឹងទទួលបានកន្លែងអង្គុយមុន។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរសព្ទដៃ ៖ +៨៥៥(០)១២ ៤៨៨ ០២៣
ទូរសព្ទ ៖ +៨៥៥(០)២៣ ២១៩ ៨៤១ លេខបន្ត ៦១៩៦
សារអេឡិចត្រូនិក ៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃ ៖ +៨៥៥(០)១២ ៤៨៣ ២៨៣
សារអេឡិចត្រូនិក ៖ neth.pheaktra@eccc.gov.kh


*ការបដិសេធ ៖ ព័ត៌មាននេះ ត្រូវបានរៀបចំឡើងសម្រាប់ជូនដំណឹងដល់ប្រព័ន្ធផ្សព្វផ្សាយ និង សាធារណជនអំពីដំណើរការនីតិវិធីដែលកំពុងបន្ត។ ព័ត៌មាននេះ គឺមិនមែនជាឯកសារផ្លូវការឡើយ។*